N. 36
30.9.02

# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


២៣-៩-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០៩០២/២៧០ ស្តីពីការតែងតាំងឯកឧត្តម **ជិន សារិន** ជាជំនួយការផ្ទាល់របស់ សម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ អគ្គនាយក ២៩១០


## II-ក្រុមប្រឹក្សាធម្មនុញ្ញ


១៩-៩-២០០២ - សេចក្តីសំរេចលេខ ០៤៩/០០៤/២០០២ កបធ.ច ២៩១១


## III-រាជរដ្ឋាភិបាល


២៥-៩-២០០២ - អនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពីការបង្កើតទិវាមច្ឆជាតិ ២៩១៥

២៣-៩-២០០២ - អនុក្រឹត្យលេខ ៤៦០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៩១៧

២៥-៩-២០០២ - អនុក្រឹត្យលេខ ៤៦១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៩១៩

២៥-៩-២០០២ - អនុក្រឹត្យលេខ ៤៦២ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ២៩២០

២៥-៩-២០០២ - អនុក្រឹត្យលេខ ៤៦៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ២៩២១

២៥-៩-២០០២ - អនុក្រឹត្យលេខ ៤៦៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៩២២

២៥-៩-២០០២ - អនុក្រឹត្យលេខ ៤៦៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៩២៣

២៥-៩-២០០២ - អនុក្រឹត្យលេខ ៤៦៦ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៩២៤

២៥-៩-២០០២ - អនុក្រឹត្យលេខ ៤៦៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៩២៥

២៥-៩-២០០២ - អនុក្រឹត្យលេខ ៤៦៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៩២៧

២៥-៩-២០០២ - អនុក្រឹត្យលេខ ៤៦៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៩២៨

២៥-៩-២០០២ - អនុក្រឹត្យលេខ ៤៧០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៩២៩

២៦-៩-២០០២ - អនុក្រឹត្យលេខ ៤៧១អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៣០

២៦-៩-២០០២ - អនុក្រឹត្យលេខ ៤៧២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៩៣១

២៦-៩-២០០២ - អនុក្រឹត្យលេខ ៤៧៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៩៣២

២៦-៩-២០០២ - អនុក្រឹត្យលេខ ៤៧៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៩៣៣

២៧-៩-២០០២ - អនុក្រឹត្យលេខ ៤៧៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៩៣៤

៣០-៩-២០០២ - អនុក្រឹត្យលេខ ៤៧៦ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៣៥
៣០-៩-២០០២ - អនុក្រឹត្យលេខ ៤៧៧ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៣៦
៣០-៩-២០០២ - អនុក្រឹត្យលេខ ៤៧៨ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៣៧
៣០-៩-២០០២ - អនុក្រឹត្យលេខ ៤៧៩ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៣៩
៣០-៩-២០០២ - អនុក្រឹត្យលេខ ៤៨០ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៤០
៣០-៩-២០០២ - អនុក្រឹត្យលេខ ៤៨១ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៤១

## IV- ការងារបណ្តាក្រសួង

### ១-ធនាគារជាតិនៃកម្ពុជា

១៣-៩-២០០២ - ប្រកាសលេខ ធ-៧-០២-១៨៦ ប្រក ស្តីពីចំណាត់ថ្នាក់និងសវិធានធនលើឥណទានអនុវត្ត ចំពោះធនាគារឯកទេសឥណទានជនបទ និងគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ២៩៤២
១៣-៩-២០០២ - ប្រកាសលេខ ធ- ៧-០២-១៨៧ ប្រក ស្តីពីវិសោធនកម្មលើប្រកាសស្តីពីសាច់ប្រាក់ងាយស្រួល របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ២៩៤៨

### ២- ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

២៦-៩-២០០២ - សេចក្តីជូនដំណឹងលេខ ១៦ សកបយ ស្តីពីការចុះបញ្ជីកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាព ជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត ២៩៥២

# ព្រះរាជក្រឹត្យ

## យើង

នស / រកត / ០៩០២/២៧០

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងឯកឧត្តម **ឌិន សារិន** ជាជំនួយការផ្ទាល់របស់ **សម្តេចប្រធានព្រឹទ្ធសភា** មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០២

**ឆ្លងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និង ត្រា**

**ជា ស៊ីម**

លេខ: ១៩៥៤ ច ល

៣១ល.២៧.០៩.០២៨៦

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០២

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ិន សេរី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ ០៥៤/០០៨/២០០២

ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០២

**សេចក្ដីសំរេច**

លេខ ០៤៩/០០៤/២០០២ កបធ.ច

ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានឃើញសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ ស្ដីពីការបកស្រាយវាក្យខ័ណ្ឌទី ១ នៃមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ
- បានឃើញលិខិតប្រធានព្រឹទ្ធសភាស្ដីទីលេខ ១៥២ / ០៩០២ / ពស /នវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី កថាខ័ណ្ឌទី ២ និងទី ៥ នៃរដ្ឋធម្មនុញ្ញ ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ប្រធានព្រឹទ្ធសភាស្ដីទីបានសុំក្នុងលិខិតលេខ ១៥២/០៩០២/ពស/នវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ ឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី កថាខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ត្រង់សេចក្ដីថា " បើព្រឹទ្ធសភា...ពុំបានឱ្យយោបល់សោះ " ហើយនិងកថាខ័ណ្ឌទី ៥ ដែលមានសេចក្ដីថា " បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ

រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ " ។

- យល់ឃើញថា សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងការបកស្រាយរដ្ឋធម្មនុញ្ញមានចែងក្នុងមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និងក្នុងមាត្រា១៥ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ ។

តាមមាត្រា ១៤១ ថ្មី ក្នុងចំណោមឥស្សរជនដែលអាចលើកសំណើសុំបកស្រាយរដ្ឋធម្មនុញ្ញគឺមានប្រធានព្រឹទ្ធសភាផងដែរ ។

ដូច្នេះ យោងតាមមាត្រា ១៣៦ ថ្មី និង ១៤១ ថ្មី នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលពិនិត្យសំណើសុំបកស្រាយមាត្រា១១៣ថ្មីកថាខ័ណ្ឌទី២ និងទី៥ របស់ប្រធានព្រឹទ្ធសភាស្តីទីខាងលើនេះបាន ។

- យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទីសុំឱ្យបកស្រាយជាដំបូង កថាខ័ណ្ឌទី ២នៃមាត្រា ១១៣ ថ្មី ត្រង់ពាក្យថា "បើព្រឹទ្ធសភា...ពុំបានឱ្យយោបល់សោះ " ។

តាមបទប្បញ្ញត្តិដែលមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រា ១១៣ថ្មី ព្រឹទ្ធសភាត្រូវពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្នុងករណីធម្មតា ប៉ុន្តែបើជាការប្រញាប់ គឺត្រឹមតែ ០៥ ថ្ងៃប៉ុណ្ណោះ ។ ដូច្នេះក្នុងករណីធម្មតា ផុតរយៈពេលមួយខែ គិតពីថ្ងៃដែល "រដ្ឋសភាបានដាក់ឱ្យពិនិត្យ"បើព្រឹទ្ធសភានៅស្ងៀមស្ងាត់ឥតធ្វើអ្វី ឬឥតឆ្លើយអ្វីសោះទៅរដ្ឋសភាវិញនោះ គឺបានន័យថា " ព្រឹទ្ធសភាពុំបានឱ្យយោបល់សោះ " ។ ប៉ុន្តែពាក្យថា " ព្រឹទ្ធសភា " គឺមានន័យថា ត្រូវមានការប្រជុំពេញអង្គរបស់ព្រឹទ្ធសភាដើម្បីសំរេចថា "មិនឱ្យយោបល់ " ។

បញ្ហាដែលស្មុគស្មាញ គឺនៅត្រង់រដ្ឋសភាសុំឱ្យព្រឹទ្ធសភាពិនិត្យជា" ការប្រញាប់ " ។ ក្នុងករណីនេះ បើព្រឹទ្ធសភានៅស្ងៀមមិនឆ្លើយតបទៅវិញហួសពី ៥ ថ្ងៃ តើរដ្ឋសភាអាចយកច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះទៅប្រកាសឱ្យប្រើបានឬទេ ?

យោងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦ /០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ និងដូចមានចែងក្នុងប្រការ ៤៣ នៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភាដែរ ព្រឹទ្ធសភាមានអំណាចសំរេចខ្លួនឯងថា "យល់ព្រម ឬ មិនយល់ព្រមទុកជាការប្រញាប់ " ។ ប៉ុន្តែបើព្រឹទ្ធសភាមិនបានសំរេចអ្វីសោះ ហើយនៅស្ងាត់ស្ងៀម លើសពី ៥ ថ្ងៃ នោះ ត្រូវចាត់ទុកថា ព្រឹទ្ធសភាទទួលយល់ព្រមថា ជាការប្រញាប់ ហើយរដ្ឋសភាអាចយកច្បាប់នោះទៅប្រកាសឱ្យប្រើក្នុងរយៈពេល ៥ ថ្ងៃបាន ។ បើព្រឹទ្ធសភាក្នុងសម័យប្រជុំពេញអង្គបានសំរេចថា " ជាការប្រញាប់" តាមសំណើសុំរបស់រដ្ឋសភា ហើយក៏បានធ្វើការពិភាក្សាទៅ ស្រាប់តែមានការរាំងស្ទះដោយថាហេតុបណ្តាលឱ្យហួសរយៈពេល ៥ ថ្ងៃទៅនោះ រដ្ឋសភាក្នុងករណីនេះ អាចយកច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះទៅប្រកាសឱ្យប្រើបាន ដោយមិនចាំបាច់រង់ចាំការអនុម័តរបស់ព្រឹទ្ធសភាឡើយ ។

- យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទីបានសុំជាបន្ទាប់មកទៀតឱ្យបកស្រាយកថាខ័ណ្ឌទី ៥ នៃមាត្រា ១១៣ ថ្មី ដែលមានសេចក្តីថា "បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ " ។

កថាខ័ណ្ឌទី ៥ នេះទាក់ទងនឹងរយៈពេលនៃ "ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភា" ដែលមានចែងក្នុងកថាខ័ណ្ឌទី ៤ នៃមាត្រា ១១៣ ថ្មី ។

ក្នុងករណីព្រឹទ្ធសភាមិនឯកភាពតាមការអនុម័តដំបូងរបស់រដ្ឋសភា ព្រឹទ្ធសភាបង្វិលទៅរដ្ឋសភាជាលើកទី១ ស្នើសុំកែប្រែ ។ រដ្ឋសភាបានទទួលហើយ ប៉ុន្តែមិនឯកភាពទាំងស្រុង ឬដោយអន្លើ នឹងសំណើកែប្រែរបស់ព្រឹទ្ធសភា ក៏បង្វិលមកព្រឹទ្ធសភាវិញសុំឱ្យពិចារណាជាថ្មី ។ ព្រឹទ្ធសភាពិចារណាជាថ្មីហើយ ក៏បង្វិលទៅរដ្ឋសភាវិញ ដោយបញ្ជាក់យោបល់របស់ខ្លួនម្តងទៀត ។ បើរដ្ឋសភាមិនទាន់ឯកភាពតាមព្រឹទ្ធសភា ការបង្វិលទៅបង្វិលមកអាចបន្តទៅទៀតបាន ជាធម្មតាក្នុងរយៈពេលមួយខែសំរាប់ពិនិត្យច្បាប់ផ្សេង ៗ ក្រៅពីច្បាប់ថវិកាជាតិ និងហិរញ្ញវត្ថុ ដែលត្រូវកំរិតត្រឹម ១០ ថ្ងៃ ។ បើជាការប្រញាប់ រយៈពេលនេះមកនៅត្រឹម ២ ថ្ងៃតែប៉ុណ្ណោះ។ រយៈពេលនៃការបង្វិលនេះត្រូវគិតពីថ្ងៃបង្វិលលើកទី ១ របស់ព្រឹទ្ធសភា ។

ពាក្យថា " បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ "បានន័យថា ក្រោយបានទទួលការសុំឱ្យកែសំរួលសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះពីព្រឹទ្ធសភាទៅ រដ្ឋសភាមិនបានធ្វើអ្វីសោះរហូតផុត ១ ខែ ឬ ១០ ថ្ងៃ ឬ ២ថ្ងៃទៅតាមករណីនីមួយៗ ដូចបានរៀបរាប់ខាងលើ ។

ពាក្យថា " ពន្យារពេលដែលកំណត់ទុក " បានន័យថា រដ្ឋសភាបានធ្វើការប្រជុំពេញអង្គសំរេចពន្យារពេលពិនិត្យឱ្យលើសពី ១ ខែ ឬ ១០ ថ្ងៃ ឬ ២ ថ្ងៃ ទៅតាមករណីនីមួយៗនោះ ។

ពាក្យថា " *រយៈពេលជាគោលការណ៍* សំរាប់រដ្ឋសភា និងព្រឹទ្ធសភា " នោះ គឺរយៈពេល ១ ខែ ឬ ១០ថ្ងៃ ឬ ២ ថ្ងៃ នេះហើយ ។

ពេលវេលាដែលលើសពីរដ្ឋធម្មនុញ្ញកំណត់ ដោយសារការទុក ឬការសំរេចពន្យាររបស់រដ្ឋសភានេះត្រូវបន្ថែមឱ្យព្រឹទ្ធសភា ឱ្យបានស្មើគ្នានឹងរដ្ឋសភាដែរ ។ ក្នុងការអនុវត្តន៍ជាក់ស្តែង ដើម្បីឱ្យបានស្មើគ្នាគេត គេត្រូវរាប់ចំនួនថ្ងៃដែលរដ្ឋសភាបានប្រើប្រាស់ ក្នុងរយៈពេលទាំងនោះ ដើម្បីឱ្យដឹងច្បាស់ សំរាប់គិតចំនួនថ្ងៃដែលព្រឹទ្ធសភាត្រូវមានស្មើគ្នាដែរ ។

ដូច្នេះក្នុង " *រយៈពេលជាគោលការណ៍ ១ ខែ* " រដ្ឋសភាមានសិទ្ធិប្រើប្រាស់ ១៥ ថ្ងៃ ចំណែកឯព្រឹទ្ធសភា ក៏១៥ ថ្ងៃ ដូចគ្នាដែរ ។ បើរដ្ឋសភាប្រើពេលលើសថែម ឧបមាថា ៣ ថ្ងៃ ខាងព្រឹទ្ធសភាក៏ត្រូវមានសិទ្ធិបន្ថែម ៣ ថ្ងៃទៀត ដូច ៗ គ្នា ។

របៀបគិតនេះ ត្រូវអនុវត្តដូចគ្នាចំពោះ " *រយៈពេលជាគោលការណ៍ ១០ ថ្ងៃ* " និង " *រយៈពេលជាគោលការណ៍ ២ ថ្ងៃ* " ទៅតាមករណីជាយថាហេតុ ។

ជារួមគេត្រូវចែក " *រយៈពេលជាគោលការណ៍* " នីមួយៗជាពីរស្មើគ្នា គឺថាបើ " *១០ ថ្ងៃ* " គឺ ៥ ថ្ងៃសំរាប់រដ្ឋសភា ហើយនិង ៥ ថ្ងៃទៀតសំរាប់ព្រឹទ្ធសភា ។ បើ " *២ ថ្ងៃ* " គឺ " *១ ថ្ងៃ* " សំរាប់រដ្ឋសភា និង " *១ ថ្ងៃ* " ទៀតសំរាប់ព្រឹទ្ធសភា ។ ហើយបើរដ្ឋសភាបន្ថែមលើសប៉ុន្មានថ្ងៃ ព្រឹទ្ធសភាក៏មានសិទ្ធិបន្ថែមចំនួនថ្ងៃលើសឱ្យស្មើគ្នានឹងរដ្ឋសភាដូចគ្នា ។

គួរកត់សំគាល់ម្យ៉ាងទៀតថា " *រយៈពេលជាគោលការណ៍* " ទាំងអស់នេះ សុទ្ធតែជា " *រយៈពេលមិនគត់* " ដែលគេត្រូវអនុវត្តតាមវិធានដែលមានចែងក្នុងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ ។

## សំរេច

**មាត្រា ១ :** មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី ២ ត្រង់ពាក្យថា " បើព្រឹទ្ធសភា ... ពុំបានឱ្យយោបល់សោះ " និងកថាខ័ណ្ឌទី ៥ ត្រូវបកស្រាយ ដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២ :** សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ៩៩ អនក្រ. បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតទិវាមច្ឆជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ៣៣ក្រ.ច ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៨៧ ស្ដីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ. បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២

## សម្រេច

**មាត្រា ១.–**

ត្រូវបានបង្កើត "**ទិវាមច្ឆជាតិ**" នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រារព្ធធ្វើឡើង នៅទូទាំងប្រទេស នា ថ្ងៃទី ០១ ខែ កក្កដា ជារៀងរាល់ឆ្នាំ ក្នុងគោលបំណងបំផុសប្រជារាស្ត្រ ចូលរួមចំណែកការពារ អភិរក្ស និង អភិវឌ្ឍវិស័យជលផល ក្នុងទិសដៅធានានិរន្តរភាព នៃធនធានជលផល ដើម្បីផលប្រយោជន៍សេដ្ឋកិច្ច សង្គម និង បរិស្ថាន។

**មាត្រា ២.-**

ក្នុងទិវាមច្ឆជាតិនេះ គ្រប់ក្រសួង ស្ថាប័នរដ្ឋ សាលាខេត្ត ក្រុង សហគ្រាសសាធារណៈ សហគ្រាសឯកជន សមាគម សហគមន៍ និងគ្រឹះស្ថានសិក្សានានា ត្រូវបំផុសមន្ត្រីរាជការ មន្ត្រីនគរបាល យោធិន និយោជិត សិស្ស និស្សិត និងប្រជារាស្ត្រ អំពីស្មារតីគោរពច្បាប់ ស្មារតីការពារធនធានជលផល ។

**មាត្រា ៣.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ គ្រប់ក្រសួង ស្ថាប័នរដ្ឋ សាលាខេត្ត ក្រុង សហគ្រាសសាធារណៈ សហគ្រាសឯកជន សមាគម និង សហគមន៍ ដើម្បីចាត់ចែងរៀបចំប្រារព្ធពិធីលែងកូនត្រី និង មច្ឆជាតិផ្សេងៗទៀត ក្នុងទិវាមច្ឆជាតិនេះឱ្យបានទូលំទូលាយ នៅគ្រប់ទីកន្លែង ដែលមាន លក្ខណៈសមស្រប ។

**មាត្រា ៤.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយគណៈកម្មការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិ អន្តរជាតិ ត្រូវរៀបចំសេចក្តី ណែនាំអំពីការប្រារព្ធទិវាមច្ឆជាតិ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលទិវាមច្ឆជាតិ ជូនរាជរដ្ឋាភិបាល រៀងរាល់ឆ្នាំ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់អភិបាលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៧០ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

### សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូននាយទាហានទីបញ្ជាការសន្តិសុខ នៃកងទ័ពភូមិន្ទថៃ ចំនួន ០៦ រូប ដែលបានសហប្រតិបត្តិការល្អប្រសើរ ក្នុងការហ្វឹកហាត់ជំនាញការពារថ្នាក់ដឹកនាំ ដល់សិក្ខាកាមនៃកងឯកភាពអង្គរក្សសម្តេច **ហ៊ុន សែន** ដូចមានរាយនាមខាងក្រោមនេះ ÷

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :**

| | |
|---|---|
| -Lt. Gen. PRAPARN NILWONG | Commanding General Armed Forces Security Center |

**ខ-មេដាយសហមេត្រី ថ្នាក់ សេនា :**

| | |
|---|---|
| 1- Maj. Gen.SOMPHON VIRASAKDI | Deputy Commanding General Armed Forces Security Center |
| 2-Maj.Gen.CHAVALIT CHARUHINDA | Assistant Commanding General Armed Forces Security Center |

**គ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ :**

| | |
|---|---|
| 1-CoL.CHAOWARIT PRAPAJIT | Director Division 8 |
| 2-CoL.NUROJ RODPOTHONG | Deputy Director Division 8 |
| 3-Maj.BORVONCHUT SUKMARK | Chief Security Officer |

**មាត្រា ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៦១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតជារាយស្ម័យយានកម្ពុជា ជាសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក **សូរ សារិទ្ធ** បច្ចុប្បន្នមន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ជាមន្ត្រីត្រួតពិនិត្យរដ្ឋអមរាជាយស្ម័យយានកម្ពុជា ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រាជាយស្ម័យយានកម្ពុជា ក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០២*

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧២ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/ ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **គុសល តិរម្យ** អត្តលេខ ០៦៥៨ អនុប្រធាននាយកដ្ឋានបុគ្គលិក នៃ ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០២*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៦៣ អនក្រ.បក

# អនុក្រឹត្យ
ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរៈសេនីយ៍ទោ **ជួន ឈឿន** អត្តលេខ ០៤៥០ អនុប្រធានអង្គភាពអន្តរាគមន៍ ។
២- លោកវរៈសេនីយ៍ទោ **សុខ ឈុន** អត្តលេខ ០២៣១០ អនុប្រធាននាយកដ្ឋានជនបរទេស ។
៣- លោកវរៈសេនីយ៍ទោ **សួន សាន់** អត្តលេខ ០៥១៦ អនុប្រធានអធិការដ្ឋានកិច្ចការនគរបាល ។
៤- លោកវរៈសេនីយ៍ទោ **ឌឹម សុផា** អត្តលេខ ០៦០៧ អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី[illegible] ខែកញ្ញា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ចំនួន ០៣ គ្រឿង ជូនអ្នកទទួលខុសត្រូវ នៃអង្គការសន្តិស្ម័គ្រចិត្ត ជប៉ុនចំនួន ០៣ រូប ដែលបានខិតខំ និង ជួយជ្រោមជ្រែងយ៉ាងសកម្ម ក្នុងការសាងសង់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យជំហានទី ២ ដូចមានរាយនាមខាងក្រោមនេះ ÷

១- ព្រះតេជគុណ **ម៉ាត់ស៊ីណាហ្គា ហ្សិនដូ** ( **Matsunaga Zendo** ) ប្រធានអង្គការសន្តិស្ម័គ្រចិត្តជប៉ុន នៅតូក្យូ

២- លោក **ណៃតូ រីយ៉ូ** ( **Naito Ruo** ) ប្រធានអង្គការសន្តិស្ម័គ្រចិត្តជប៉ុនប្រចាំកម្ពុជា

៣- លោក **កាតូ សាកាអេ** ( **Kato Sakae** ) អតីតប្រធានអង្គការសន្តិស្ម័គ្រចិត្តជប៉ុន ប្រចាំកម្ពុជា

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៤៦៥...អនក្រ-តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន ០១ គ្រឿង ជូនលោក **យី ធន់ (Yi Thon)** នាយកគំរោងសាងសង់ អគារពុទ្ធសាសនបណ្ឌិត្យជំហាន ទី ២ ដែលមានស្នាដៃល្អ ក្នុងការសាងសង់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ចំនួន ០១ គ្រឿង ជូនលោកស្រីបណ្ឌិត **ហេម៉ា ហ្គោណាតេឡេក** ( **Dr. Hema Gonatelleke** ) តំណាងមូលនិធិហ៊ានិរិចបូល នៃប្រទេសអាល្លឺម៉ង់ ប្រចាំកម្ពុជា ដែលបានផ្តល់ មូលនិធិជាច្រើន ក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស និង បានជួយទាំងថវិកា និង បច្ចេកទេសដល់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៦ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ជូនអ្នកបច្ចេកទេស និង សាស្ត្រាចារ្យ នៃអង្គការ JICA ចំនួន ០៧ រូប ដែលមានគុណបំណាច់ខ្ពស់ និង ស្នាដៃល្អ ក្នុងការអនុវត្តគំរោងជំនួយចំពោះមហាវិទ្យាល័យគរុកោសល្យ រួមមានការកសាងអគារថ្មី បំពាក់សម្ភារៈបរិក្ខារទំនើបៗ និង បណ្តុះបណ្តាលគ្រូវិទ្យាសាស្ត្រ និង គណិតវិទ្យាកម្ពុជា ដូចមានរាយនាមខាងក្រោម ÷

**ក-មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា :**

១-លោកបណ្ឌិត **WAKABAYASHI Mitsuru**

២-លោក **MURATA Ryuichi** ប្រធានក្រុមបច្ចេកទេស

៣-លោក **KIKUCHI Hiroshi** អ្នកបច្ចេកទេស

**ខ-មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ :**

១-លោក **TAKAHACHI Koji** សាស្ត្រាចារ្យគណិតវិទ្យា

២-កញ្ញា **MAEDA Mitsuko** សាស្ត្រាចារ្យវិទ្យាសាស្ត្រ

៣-លោក **SHIKE Akihiko** សាស្ត្រាចារ្យរូបវិទ្យា

៤-លោក **MURAYAMA Tetsuya** សាស្ត្រាចារ្យជីវវិទ្យា

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង អប់រំយុវជន និង កីឡា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៤៧៨...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

&&&&&

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

**ស ំ រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនអង្គការ JICA នៃប្រទេសជប៉ុន ដែលបានផ្តល់ជំនួយជាអគារសិក្សា សម្ភារៈបច្ចេកទេស អ្នកបច្ចេកទេស និង សាស្ត្រាចារ្យ សំរាប់បណ្តុះបណ្តាលគ្រូវិទ្យាសាស្ត្រ និង គណិតវិទ្យា នៅមហាវិទ្យាល័យគរុកោសល្យ ពី ឆ្នាំ ២០០០ ដល់ ២០០៣ ចំណាយអស់ថវិកាសរុបប្រមាណ ៤.៩៧៧.២០១ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង អប់រំយុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៦៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គលេខាធិការ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ វិស័យបច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **Ramesh Chandran** អនុប្រធានអង្គការ UNDP ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានគុណបំណាច់ខ្ពស់ និង ស្នាដៃល្អ ក្នុងការរួមចំណែកជួយស្តារ និង អភិវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជា លើគ្រប់វិស័យ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គលេខាធិការ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ វិស័យបច្ចេកវិទ្យាគមនាគមន៍ ពត៌មានវិទ្យា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧២០ អនក្រ-កត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ព្រះមហាសុមេធាធិបតីសម្តេចព្រះសង្ឃរាជគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោកគ្រូខេមរៈមហាចក្រ **ម៉ៅ រិទ្ធីថា** ប្រធានសមាគមពុទ្ធសាសនូបត្ថម្ភ សង្គ្រោះចាស់ជរា ជនក្រីក្រ និង ក្មេងកំព្រា ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងការចូលរួមស្តារ និង កសាងវិស័យ សង្គមកិច្ច វប្បធម៌ និង ព្រះពុទ្ធសាសនា ។

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៧១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ពានជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ពានជាតិ** ចំនួន ០២ គ្រឿង ជូនសប្បុរសជនជនជាតិជប៉ុន ០២រូប ដែលបានបរិច្ចាគអំណោយ ជាតុ និង កៅអី លើវិស័យសិក្សាធិការ សំរាប់ចែកជូនសាលានានា ក្នុងរាជធានីភ្នំពេញ ក្នុងនោះមាន ÷

១-លោក **DOBASHI NOBUO** អភិបាលក្រុង **Sapporo** បានជួយឧបត្ថម្ភតុចំនួន ៨.៣៥៤ និង កៅអីចំនួន ៧.៨៤៥ អស់ទឹកប្រាក់ចំនួន ៩៧.៧០៣ ដុល្លារអាមេរិក ។

២-លោក **YOSHIO AIKAWA** អភិបាលក្រុង **Tomisato** បានជួយឧបត្ថម្ភតុចំនួន ៩១៧ និង កៅអីចំនួន ៩១៥ អស់ទឹកប្រាក់ចំនួន ១០.៩៩៤ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាល-ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:....៤៧៨....អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោក **ប៊ុក ចន្ទរិទ្ធិ** អនុមន្ត្រីថ្នាក់លេខ ៦ អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ដែលមានស្នាដៃ និង គុណបំណាច់ខ្ពង់ខ្ពស់ ក្នុងការបំរើជាតិមាតុភូមិ ហើយបានទទួលមរណភាពដោយរោគាពាធ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៧៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោក **អោម ហាន** អនុមន្ត្រីថ្នាក់លេខ ៥ អភិបាលស្រុកត្រាំកក់ ខេត្តតាកែវ ដែលកន្លងមកលោកបានបូជាកំលាំងកាយចិត្ត កំលាំងបញ្ញា ចូលរួមយ៉ាងសកម្មក្នុងការបំរើប្រទេសជាតិ ហើយបានទទួលមរណភាព កាលពីថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៧៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

**ស ម្រ េ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន ០៥ គ្រឿង ជូនមន្ត្រីរាជការ ចំនួន ០៥ រូប នៃក្រសួងធម្មការ និង សាសនា ដែលបានខិតខំទំនាក់ទំនងយ៉ាងសកម្ម ជាមួយភាគីជប៉ុន ក្នុងការសាងសង់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ជំហានទី ២ ដូចមានរាយនាមខាងក្រោមនេះ ÷

១- លោក **ខិម ខែម** ទីប្រឹក្សាអមក្រសួងធម្មការ និង សាសនា
២- លោក **ខិត ស៊ុនថន** ទីប្រឹក្សាអមក្រសួងធម្មការ និង សាសនា
៣- លោក **ឈឿន ហេង** នាយកខុទ្ទកាល័យក្រសួងធម្មការ និង សាសនា
៤- លោក **ពៅ ធនវឌ្ឍ** បណ្ណារក្សវិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យ
៥- លោក **មៀច ប៊ុណ្ណ** មន្ត្រីក្រុមជំនុំទំនៀមទំលាប់ខ្មែរ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧០ / អនក្រ.បក / ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា ១** : តែងតាំងលោក សេង ពន្លក ជាជំនួយការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា / គណៈកម្មាធិការវិនិយោគកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ៤៥៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសំរិទ្ធស្ថាបនាជាតិ** ចំនួន ០៤ គ្រឿង ជូនសប្បុរសជន ចំនួន ០៤ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងស្រះទឹក ០១កន្លែង មានទំហំ ៨៤១ ម$^2$ នៅវត្តច័ន្ទនិមិត្ត ស្រុករវៀង ខេត្តព្រះវិហារ ចំណាយអស់ទឹកប្រាក់ចំនួន ៧.៩០៨ USD និង ចំនួន ៩០.០០០ រៀល ដូចមានរាយនាមខាងក្រោមនេះ ÷

១-លោកជំទាវ ឧត្តមសេនីយ៍ត្រី **អ៊ុន សុគន្ធា**
២-លោកជំទាវ **សុខ កែវ**
៣-លោកជំទាវ **ពឹង សុភាព**
៤-លោកជំទាវ **នាង ចរិយា**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៣៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ **អ៊ី ឈាន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលក្រុងប៉ៃលិន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងអគារសិក្សា ០១ ខ្នង មាន ០៥ បន្ទប់ និង បំពាក់សំភារៈសិក្សាមួយចំនួន នៅអនុវិទ្យាល័យក្នុងទីរួមស្រុកសង្គមថ្មី ខេត្តព្រះវិហារ ចំណាយអស់ទឹកប្រាក់សរុបចំនួន ២០.២០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៣៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១៣ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងផ្លូវ ចាក់កៅស៊ូប្រវែង ១.២០០ ម៉ែត្រ នៅក្នុងស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

១-លោក **ចៅ នុច** សប្បុរសជននៅឃុំឫស្សីក្រោក ថវិកាចំនួន ១០.000 USD
២-លោក **លាភ ម៉ាន** សប្បុរសជននៅឃុំឫស្សីក្រោក ថវិកាចំនួន ១០.000 USD
៣-លោក **នុយ ជាន** សប្បុរសជននៅឃុំឫស្សីក្រោក ថវិកាចំនួន ១០.000 USD

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-លោក **អ៊ុច សារុន** សប្បុរសជននៅឃុំឫស្សីក្រោក ថវិកាចំនួន ១.000 USD
២-លោក **សេង ធឿន** សប្បុរសជននៅឃុំឫស្សីក្រោក ថវិកាចំនួន ១.000 USD
៣-លោក **ណុប នួច** សប្បុរសជននៅឃុំអូរប្រាសាទ ថវិកាចំនួន ១.000 USD
៤-លោក **ប្រាក់ សារ៉ាក់** សប្បុរសជននៅឃុំអូរប្រាសាទ ថវិកាចំនួន ១.000 USD
៥-លោក **កែវ ឡាំ** សប្បុរសជននៅខេត្តបន្ទាយមានជ័យថវិកាចំនួន ១.000 USD

៦-លោក **តាំង ម៉ុនឃាង** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១.០០០ USD

៧-លោក **ទ៉ា ហ្វាត** សប្បុរសជននៅឃុំបន្ទាយនាង ថវិកាចំនួន ១.០០០ USD

៨-លោក **ជា សាង** សប្បុរសជននៅឃុំភ្នំតូច ថវិកាចំនួន ១.០០០ USD

៩-លោក **ផាទ ខួន** សប្បុរសជននៅឃុំឫស្សីក្រោក ថវិកាចំនួន ១.០០០ USD

១០-លោក **ចៅ ឫទ្ធីហាង** សប្បុរសជននៅឃុំឫស្សីក្រោក ថវិកាចំនួន ១.០០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយ - មានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

✓✓*✓✓

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៣ រូប ដែលបាន បរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាងព្រះវិហារ និងសំណង់ផ្សេងៗ នៅក្នុងវត្តឃីឡិក ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក.មេដាយមាសស្ថាបនាជាតិ :**

- លោក **ជា ហឿង** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១៧.៦០០ USD

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

- លោកយាយ **ចាន់ លន់** ហៅ **សីលា** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៦.១០០ USD

**គ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

- លោក **គាំ ហ៊ុយ** ថវិកាចំនួន ៣.២៣៩ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយ - មានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៤៨០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនលោក **វ៉ាត់តាណាបេមីគី** ( **WATANABEMIKI** ) និង សប្បុរសជន ជនជាតិជប៉ុន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងអគារសិក្សា ០១ ខ្នង មាន ០៥ បន្ទប់ និង បំពាក់សំភារៈសិក្សាគ្រប់គ្រាន់ នៅសាលាបឋមសិក្សាភូមិថ្មកែវ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំណាយអស់ទឹកប្រាក់សរុបចំនួន ២៨.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៨៧១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនលោក **ស៊ុយមីតាហៃ គីជី** ( SUMITAHEI KICHI ) និង សប្បុរសជនជនជាតិជប៉ុន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងអគារសិក្សា០១ ខ្នង មាន ០៥ បន្ទប់ បំពាក់សំភារៈសិក្សាគ្រប់គ្រាន់ ធ្វើបង្គន់អនាម័យ០១ខ្នង និង អណ្តូងទឹក ០១ នៅសាលាបឋមសិក្សាភូមិស្រះកែវ ឃុំមេលំ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ចំណាយអស់ទឹកប្រាក់សរុបចំនួន ៣២.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ7-02-186 ប្រ.ក

# ប្រកាស
## ស្តីពី
## ចំណាត់ថ្នាក់និងសំវិធានធនលើឥណទាន
## អនុវត្តចំពោះធនាគារឯកទេសឥណទានជនបទនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិ នៃ កម្ពុជា ជាថ្មីម្តងទៀត
- បានឃើញប្រកាសលេខធ ៧០០-០៦ ប្រ.ក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមការឯកភាពរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជានៅថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២ ។

## ស ម្រេ ច

**ប្រការ ១.-**

ធនាគារឯកទេសឥណទានជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវរៀបចំប្រព័ន្ធពត៌មានគណនេយ្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីអាចមានលទ្ធភាពផ្តល់ពត៌មានជាអចិន្ត្រៃយ៍ដល់ធនាគារជាតិនៃកម្ពុជា ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

## ប្រការ ២.-

ធនាគារឯកទេសឥណទានជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណត្រូវធ្វើចំណាត់ថ្នាក់ឥណទានរបស់ខ្លួនជា៤ថ្នាក់ ដោយផ្អែកទៅលើស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីប្រាក់ និងឥណប្រតិទាននៃការទូទាត់សងប្រាក់ដើមនិងការប្រាក់ ដូចខាងក្រោម :

- បំណុលស្តង់ដារ: ស្ថានភាពហិរញ្ញវត្ថុល្អ និងការសងទៀងទាត់នៃប្រាក់ដើមនិងការប្រាក់ ។
- បំណុលក្រោមស្តង់ដារ : ការសងប្រាក់ដើមនិង/ឬ ការប្រាក់ហួសកាលកំណត់៣០ថ្ងៃឬច្រើនជាង ។
- បំណុលសង្ស័យ : ការសងប្រាក់ដើម និង/ឬ ការប្រាក់ហួសកាលកំណត់ ដូចខាងក្រោម÷
  - ៦០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទាន១ឆ្នាំ ឬតិចជាង១ឆ្នាំ ។
  - ១៨០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទាន លើសពី១ឆ្នាំ ។
- បំណុលបាត់បង់ : ការសងប្រាក់ដើម និង/ឬ ការប្រាក់ហួសកាលកំណត់ ដូចខាងក្រោម÷
  - ៩០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទាន១ឆ្នាំ ឬតិចជាង១ឆ្នាំ ។
  - ៣៦០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទាន លើសពី១ឆ្នាំ ។

## ប្រការ ៣.-

ធនាគារឯកទេសឥណទានជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើសវិធានធនលើឥណទានដូចខាងក្រោម÷

- បំណុលក្រោមស្តង់ដារ :១០% ដោយមិនគិតដល់តំលៃទ្រព្យសម្បត្តិដែលបានដាក់បញ្ចាំ លើកលែងតែសាច់ប្រាក់
- បំណុលសង្ស័យ : ៣០%ដោយមិនគិតដល់តំលៃទ្រព្យសម្បត្តិដែលបានដាក់បញ្ចាំ លើកលែងតែសាច់ប្រាក់
- បំណុលបាត់បង់ : ១០០% បើគ្រឹះស្ថានអាចបង្ហាញភស្តុតាងតាមករណីនិមួយៗនូវតំលៃទីផ្សារជាក់ស្តែងនៃទ្រព្យសម្បត្តិដែលបានដាក់ជាវត្ថុបញ្ចាំ និងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ចំនួនឥណទានដែលពុំមានសំភារៈធានា ត្រូវធ្វើសវិធានធន ។

សវិធានធនត្រូវបានគណនាតាមសមតុល្យឥណទានដែលបានធ្វើចំណាត់ថ្នាក់ ដោយមិនគិតបញ្ចូលការប្រាក់បង្គរ ។ សវិធានធនត្រូវបានកត់ត្រាក្នុងគណនីរបស់គ្រឹះស្ថាន ហើយគិតបញ្ចូលទៅក្នុងគណនីចំណេញ-ខាត ក្នុងខែដែលឥណទានត្រូវបានធ្វើចំណាត់ថ្នាក់ក្រោមស្តង់ដារ ។

**ប្រការ ៤.-**

ការប្រាក់បង្គរលើឥណទានត្រូវកត់ត្រាជាចំណូលក្នុងគណនីចំណេញ-ខាតនៅពេលកត់ត្រាបង្គរ ។ ប៉ុន្តែចំពោះឥណទានដែលបានធ្វើចំណាត់ថ្នាក់ក្រោមស្តង់ដារ និងការប្រាក់បង្គរដែលមិនបានសងពេលនេះនឹងត្រូវផ្ទេរចេញពីគណនីចំណេញ-ខាត ហើយយកទៅចុះឥណទានក្នុងគណនីព្យួរទុក ។ ដូចគ្នានេះដែរ ការប្រាក់បង្គរលើឥណទានណាមួយបន្ទាប់ពីបានធ្វើចំណាត់ថ្នាក់ក្រោមស្តង់ដារនឹងត្រូវចុះឥណទានក្នុងគណនីព្យួរទុក ។

**ប្រការ ៥.-**

គ្រឹះស្ថានណាដែលមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៦.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់ធនាគារឯកទេសឥណទានជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២

**ទេសាភិបាល**

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.02...186...Prov...Kor

Unofficial translation not finalized

# PRAKAS
# ON
# LOAN CLASSIFICATION AND PROVISIONING APPLICABLE TO SPECIALIZED BANKS FOR RURAL CREDIT AND LICENSED MICROFINANCE INSTITUTIONS

------

The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia,
- With reference to the Royal Kram NS/RKM/ 0196/27 of January 26, 1996 promulgating the Law on the Organization and Functioning of the National Bank of Cambodia,
- With reference to the Royal Kram NS/RKM/ 1199/13 of November 18,1999 promulgating the Law on Banking and Financial Institutions,
- With reference to the Royal Decree NS/RKT/0202/039 of February 16, 2002 on the reappointment of His Excellency Chea Chanto as Governor General of the National Bank of Cambodia,
- With reference to the PRAKAS No. B 700-06 Pror Kor of January 11, 2000 on Licensing of Micro-finance Institution,
- Pursuant to the agreement of the leader meeting of the National Bank of Cambodia on August 06, 2002.

## Decides

**Article 1** Specialized banks for rural credit and licensed microfinance institutions must organize their internal accounting system in such a way that they are able at any time to provide the National Bank of Cambodia with information in accordance with the provisions of this Prakas.

**Article 2** Specialized banks for rural credit and licensed microfinance institutions shall classify their loan portfolio into the following four classes, depending on the financial situation of the borrower and the timeliness of principal and interest payments:

- ***Standard***: good financial condition and punctual payment of principal and interest
- ***Sub-standard***: some payments of principal and /or interest are overdue by 30 days or more

malay/ongoing/Prakas on classify and provision

P.O BOX 25, 22-24 Preah Norodom Blvd., Phnom Penh, Cambodia
Phone : 855 23 722563
Fax/Phone : 855 23 426117

- ***Doubtful***: some payments of principal and/ or interest are overdue as follows:

- 60 days or more in the case of a loan with an original term of one year or less than one year.
- 180 days or more in the case of a loan with an original term more than one year.

- *Loss*: some payments of principal and/or interest are overdue as follows:
- 90 days or more in the case of a loan with an original term of one year or less than one year.
- 360 days or more in the case of a loan with an original term more than one year.

**Article 3** Specialized banks for rural credit and licensed microfinance institutions shall take specific provisions on loans classified as follows:

- substandard: 10% regardless of the collateral value except cash.
- doubtful : 30% regardless of the collateral value except cash.
- loss: 100% if the institutions can prove the market value of collateral on the case by case basis, acceptable to the National Bank of Cambodia, only part of loans uncovered will be provisioned.

The provisions will be calculated as a percentage of the loan amount outstanding at the time the loan is classified, excluding accrued interest. The provisions shall be recorded in the institution's accounts and charged to the profit and loss account for the month during which the corresponding loan has been classified below *standard*.

**Article 4** In accordance with the accrual method of accounting, interest accrued on a loan shall be recorded as income in the profit and loss account for corresponding period. However, in the case of loans classified below *standard*, accrued interest that has not actually been paid will be reversed and credited to a suspense account. Likewise, interest accrued on a loans after it has been classified below *standard* will be credited to the same suspense account.

**Article 5** Violations to the provisions of this Prakas may give rise to disciplinary sanctions as set forth in Article 52 of the *law on Banking and Financial Institutions*.

**Article 6** All provisions contrary to this Prakas are hereby repealed.

**Article 7** The General Direction, the General Secretariat, the General inspection, the General Cashier and all departments of the National Bank of Cambodia, all Specialized banks for rural credit and licensed microfinance institutions under of the National Bank of Cambodia supervisory authority shall strictly implement this Prakas.

**Article 8** This Prakas shall have effect from the signing date.

Phnom Penh...13....09...............2002
Governor
Signed and sealed: CHEA CHANTO

cc: - The member of the Board of directors
- The parties concerned as stated in Article 7
- File
- CM " for info "
- Administration
- Department of CM
" for publication in the National Gazette "

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិនៃកម្ពុជា**

លេខ ធ7-02-187 ប្រក

# ប្រកាស
## ស្តីពី
## វិសោធនកម្មលើប្រកាស
## ស្តីពី
## សាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- បានឃើញប្រកាសលេខ ធ ៧-០០-៣៨ ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមការឯកភាពរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០២ ។

## សំរេច

**ប្រការ ១ :**

ធ្វើវិសោធនកម្មប្រការ៦ នៃប្រកាសលេខ ធ ៧-០០-៣៨ ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានខ្លឹមសារដូចខាងក្រោម ÷

នៅរៀងរាល់ពេល ធនាគារត្រូវមានអនុបាតសាច់ប្រាក់ងាយស្រួលយ៉ាងតិចបំផុត ៨០ ភាគរយ ។

**ប្រការ ២ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ៣ :**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី 13 ខែ កញ្ញា ឆ្នាំ២០០២

**ទេសាភិបាល**

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**KINGDOM OF CAMBODIA**
**NATION RELIGION KING**

**NATIONAL BANK OF CAMBODIA**

Number..B7-02...187.......Prar.Kor

# PRAKAS
## on
## Amendement of Prakas

## RELATING TO LIQUIDITY FOR BANKS AND FINANCIAL INSTITUTIONS

---

**The Governor of the National Bank of Cambodia,**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27 of January 26. 1996 promulgating the Law on the organization and conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18. 1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/ RKT/0202/039 of February 16, 2002 on the reappointment of His Excellency Chea Chanto as Governor of the National Bank of Cambodia;
- With reference to the Prakas No B7-00-38 relating to liquidity for banks and financial institutions;
- Pursuant to the agreement of the leader meeting of the National Bank of Cambodia on August 06, 2002.

## DECIDES

**Article 1:** Article 6 of Prakas No B7-00-38, dated February 09, 2000 relating to liquidity for banks and financial institutions is amended and has the following content:

Banks must at all times have a liquidity ratio of at least 80 percent.

P.O BOX 25, 22-24 Preah Norodom Blvd., Phnom Penh, Cambodia
Phone : 855 23 722563
Fax/Phone : 855 23 426117

**Article 2:** The General Direction, the General Secretariat, the General Cashier, the General Inspection, all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the NBC's supervisory authority shall implement this Prakas.

**Article 3:** This Prakas shall have effect from the signing date.

Phnom Penh, 13 . 09 , 2002

**The Governor**

**Signed and sealed: CHEA CHANTO**

cc: - The Members of the Board of Directors
- CM "for information"
- Administration Department of CM "for publication in the National Gazette"

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MOSALVY

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ:......១៧......សកបយ.

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កញ្ញា ឆ្នាំ២០០២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និង ការបញ្ជាក់ភាពជាតំណាង របស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត

ផ្អែកតាមច្បាប់ស្តីពីការងារ ប្រកាសលេខ២៧៧សកបយ. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០០ ស្តីពីការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងប្រកាសលេខ៣០៥សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត នៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាពដើម្បីចុះអនុសញ្ញារួម នៅថ្នាក់សហគ្រាស គ្រឹះស្ថាន ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជូនដំណឹងដល់សហព័ន្ធសហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និងនិយោជកទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តន៍នៃច្បាប់ស្តីពីការងារ អោយបានជ្រាបថា :

I-ក្រសួងទើបបានបង្កើតការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ នៅចំពោះនាយកដ្ឋានអធិការកិច្ចការងារ កាលពីថ្ងៃទី២១ ខែ សីហា ឆ្នាំ២០០២ តាមប្រកាសលេខ២២២ សកបយ.។ ការិយាល័យនេះមានភារកិច្ចជាពិសេសក្នុងការទទួលសំណុំលិខិត និងចាត់ចែងការងារនៃការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ ការបញ្ជាក់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត ការចុះបញ្ជិកាកំណត់ហេតុបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក។

ការបង្កើតការិយាល័យថ្មីនេះ គឺក្នុងគោលបំណងសម្រួលដល់ការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាង របស់សហជីពអោយបានងាយស្រួល និងឆាប់រហ័ស។

II -<u>បែបបទចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត :</u>

១-<u>ការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ</u>

ស្ថាបនិកនៃសហជីពកម្មករនិយោជិត និងសមាគមនិយោជកត្រូវយកសំណុំលិខិតស្នើសុំចុះបញ្ជិកាអង្គការវិជ្ជាជីវៈ (សហជីព ឬ សមាគមនិយោជក) ទៅដាក់ជូនការិយាល័យទំនាក់ទំនងវិជ្ជាជីវៈនៃនាយកដ្ឋានអធិការកិច្ចការងារ អាសយដ្ឋានលេខ២៨ វិថីសម្តេចព្រះពុទ្ធលិខិតវរ៉ុក (ផ្លូវលេខ១៨៤) សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

សំណុំលិខិតស្នើសុំចុះបញ្ជីការអង្គការវិជ្ជាជីវៈ បានផែងពាំរពីតទៅក្នុងប្រកាសរបស់ក្រសួងលេខ២៧៧សកបយ. ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០០។

២-ការបញ្ជាក់អំពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត :

សហជីពដែលមានបំណងស្នើសុំការបញ្ជាក់អំពីភាពជាតំណាង ត្រូវដាក់ពាក្យស្នើសុំការបញ្ជាក់នេះចំនួន១១ច្បាប់ នៅការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ នៃនាយកដ្ឋានអធិការកិច្ចការងារ ដែលមានអាសយដ្ឋានដូចបានជំរាបខាងលើ។ ពាក្យស្នើសុំនេះ ត្រូវបញ្ជាក់អោយបានច្បាស់លាស់អំពីៈ-

-ឈ្មោះសហជីព

-ក្របខណ្ឌភូមិសាស្ត្រ ឬ វិជ្ជាជីវៈដែលមានបំណងស្នើសុំបញ្ជាក់ភាពជាតំណាង

-លេខ និងថ្ងៃ ខែ ឆ្នាំ វិញ្ញាបនប័ត្រចុះបញ្ជីកា និងការកែប្រែបន្តមកទៀត

-ចំនួនសមាជិករបស់សហជីព និងចំនួនកម្មករនិយោជិតសរុបក្នុងក្របខ័ណ្ឌភូមិសាស្ត្រ ឬវិជ្ជាជីវៈដែលស្នើសុំការបញ្ជាក់នេះ ព្រមទាំងធ្វើការប្រៀបធៀបជាភាគរយ

-ចំនួនសមាជិករបស់សហជីពដែលបានបង់ភាគទានសហជីព និងរូបភាពបង់ភាគទាននេះ (បង់ដោយផ្ទាល់ទៅសហជីព ឬ តាមរយៈការកាត់ប្រាក់ឈ្នួលដោយនិយោជក)

-កម្មវិធីការងាររបស់សហជីព

គំរូពាក្យស្នើសុំការបញ្ជាក់ភាពជាតំណាងបានជូនភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងនេះ។

ទន្ទឹមនេះ សហជីពសាមីត្រូវផ្តល់នូវភស្តុតាងភ្ជាប់ជាមួយពាក្យសុំការបញ្ជាក់ ដូចខាងក្រោមៈ

-សេចក្តីថតចំលងវិញ្ញាបនប័ត្រចុះបញ្ជីកាសហជីព

-ភស្តុតាងនៃការកែប្រែបន្តមកទៀត។

III- ថិរវេលានៃការចុះបញ្ជីការអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាងនៃអង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត :

ក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរ ក្រោយថ្ងៃដែលស្ថាបនិកសហជីព ឬ សមាគមនិយោជកបានយកសំណុំលិខិតស្នើសុំចុះបញ្ជីការអង្គការវិជ្ជាជីវៈ ឬ សំណើសុំបញ្ជាក់អំពីភាពជាតំណាងសហជីពទៅដាក់ជូនការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ ស្ថាបនិកសហជីព ឬ សមាគមនិយោជកសាមីត្រូវទៅជួបមន្ត្រីនៃការិយាល័យនេះ ដើម្បីទទួលដំណឹងអំពីភាពសមស្រប ឬ មិនសមស្របនៃសំណុំលិខិតស្នើសុំរបស់ខ្លួន។ ក្នុងករណីដែលសំណុំលិខិតស្នើសុំនោះមានភាពមិនសមស្របត្រង់ចំណុចណាមួយ ស្ថាបនិកនៃសាមីអង្គការវិជ្ជាជីវៈត្រូវទទួលយកសំណុំលិខិតនោះទៅធ្វើការកែសម្រួល ឬ បំពេញបន្ថែមអោយបានត្រឹមត្រូវ រួចហើយទើបយកទៅ ដាក់ជូនជាថ្មីទៀតនៅការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ។ រយៈពេលនៃការទទួលយកសំណុំលិខិតរបស់ខ្លួនទៅកែសម្រួល ឬ បំពេញបន្ថែមនោះ មិនគិតចូលក្នុងថិរវេលានៃការពិនិត្យពាក្យស្នើសុំទាំងឡាយខាងលើនោះឡើយ។ ករណីដែលសំណុំលិខិតស្នើសុំត្រូវបានពិនិត្យឃើញថាមានភាពមិនសមស្រប ហើយម្ចាស់សំណុំលិខិត

មិនបានទៅជួបមន្ត្រីនៃការិយាល័យទំនាក់ទំនងវិជ្ជាជីវៈទេ មន្ត្រីនោះត្រូវផ្ញើសំណុំលិខិតនោះត្រឡប់ទៅម្ចាស់ដើមវិញ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា កំណត់ថិរវេលាអតិបរមា ២ ខែ សំរាប់រៀបចំដំណើរការការងារទាំងពីរនេះ តាមនីតិវិធីច្បាស់ ។ ថិរវេលា២ខែនេះនឹងត្រូវពន្យា ក្នុងករណីមានការប្តឹងជំទាស់តវ៉ា ឬ ហេតុផលចាំបាច់ណាមួយជាយថាហេតុ ដែលទាមទារអោយមានការងារបន្ត ។

**IV-នីតិវិធីនៃការតវ៉ាចំពោះការយឺតយ៉ាវនៃការដោះស្រាយសំណុំរឿង :**

ក្នុងករណីពិនិត្យឃើញថា មានការយឺតយ៉ាវក្នុងការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការចេញលិខិតបញ្ជាក់ពីភាពជាតំណាងអង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត ខុសពីថិរវេលាខាងលើ ម្ចាស់សំណុំរឿងអាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅនាយកដ្ឋានអធិការកិច្ចការងារ ។ ក្រោយពីដាក់ពាក្យតវ៉ានេះរយៈពេល២សប្តាហ៍ បើគ្មានការបំភ្លឺសមស្របពីនាយកដ្ឋានអធិការកិច្ចការងារទេ ម្ចាស់សំណុំរឿងអាចធ្វើការតវ៉ាដោយផ្ទាល់ទៅអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ ទៅរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសង្ឃឹមយ៉ាងមុតមាំថា សហព័ន្ធសហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និង និយោជកទាំងអស់នឹងខិតខំសហការជាមួយក្រសួងដើម្បីអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។៚

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**អ៊ិត សំហេង**

**<u>ចម្លងជូន</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា ខេត្ត-ក្រុង
" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
-សមាគមនិយោជក
-សហព័ន្ធសហជីព
" ដើម្បីជ្រាប "
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងលេខ:................សកបយ.

ចុះថ្ងៃទី............ខែ............ឆ្នាំ២០០២ ស្តីពីសំណើសុំការចុះបញ្ជិការអង្គការវិជ្ជាជីវៈ

និងការបញ្ជាក់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត

"ពាក្យស្នើសុំ"

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សហព័ន្ធសហជីព....................**

**សហជីព.........................** រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០២

**ប្រធានសហជីព................................................**

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**__កម្មវត្ថុ__** : សំណើសុំភាពជាតំណាង☐ ភាពជាតំណាងបំផុត☐របស់អង្គការវិជ្ជាជីវៈនៃកម្មករ និយោជិត

**__យោង__** : -ច្បាប់ស្តីពីការងារ

-ប្រកាសលេខ៣០៥សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈ នៃកម្មករនិយោជិតនៅថ្នាក់សហគ្រាសគ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់ សហគ្រាស គ្រឹះស្ថាន

-សេចក្តីជូនដំណឹងលេខ...........សកបយ. ចុះថ្ងៃទី..........ខែ.............ឆ្នាំ២០០២ ស្តីពីការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករ និយោជិត ។

សេចក្តីដូចមានចែងនៅក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីបានជ្រាបថា ដើម្បីបានភាពជាតំណាងក្នុងការចរចាជាសមូហភាព ការចុះអនុសញ្ញារួម និងការធានាដោះស្រាយបញ្ហាផ្សេងៗជាមួយនិយោជក ខ្ញុំសូមគោរពស្នើសុំឯកឧត្តមរដ្ឋមន្ត្រីមេត្តាបញ្ជាក់ពីភាពជាតំណាង☐ភាពជាតំណាងបំផុត☐របស់សហជីពខ្ញុំបាទ/នាងខ្ញុំ ។

ពត៌មានអំពីសហជីពមានដូចខាងក្រោមនេះ:

១-ឈ្មោះអង្គការវិជ្ជាជីវៈ:.......................................................................

២-បានចុះបញ្ជិកាលេខ.................សកបយ. ចុះថ្ងៃទី......................................

៣-ក្របខណ្ឌ ភូមិសាស្ត្រ ឬ វិជ្ជាជីវៈរបស់អង្គការវិជ្ជាជីវៈ និងវិជ្ជាជីវៈ

-ឈ្មោះសហគ្រាស គ្រឹះស្ថានៈ.............................................................................................

-ទូទាំងសហគ្រាស គ្រឹះស្ថាន ☐

-វិជ្ជាជីវៈខ្លះនៃសហគ្រាស គ្រឹះស្ថាន☐ បរិយាយៈ...............................................................

.........................................................................................................................។

៤-ចំនួនសមាជិកសហជីព.......................នាក់ និងចំនួនកម្មករសរុប.......................នាក់ (ក្នុងក្របខណ្ឌ ភូមិសាស្ត្រ ឬ វិជ្ជាជីវៈរបស់អង្គការវិជ្ជាជីវៈ និងវិជ្ជាជីវៈ)

៥-ការបង់ភាគទានៈ

-បង់ដោយផ្ទាល់ដៃ ☐ ចំនួន....................នាក់ ស្មើនឹង.............ភាគរយនៃសមាជិក

-បង់តាមរយៈនិយោជក ☐ ចំនួន.....................នាក់ ស្មើនឹង..............ភាគរយនៃសមាជិក

៦-កម្មវិធីការងាររបស់សហជីពៈ

.........................................................................................................................

.........................................................................................................................

.........................................................................................................................

៧-ជូនភ្ជាប់មកជាមួយនូវៈ

-ច្បាប់ថតចម្លងវិញ្ញាបនបត្រ័ចុះបញ្ជិកា ចំនួន ០១ច្បាប់

-.......................................................................................................

-.......................................................................................................។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ ខ្ញុំសូមស្នើសុំសេចក្ដីបញ្ជាក់ដ៏ខ្ពង់ខ្ពស់ពីឯកឧត្ដមរដ្ឋមន្ត្រី ដើម្បីបានភាពស្រប ច្បាប់ក្នុងការអនុវត្តនីតទៅ។

សូមឯកឧត្ដមមេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រ អំពីខ្ញុំ។

**ប្រធានសហជីព**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០២

បានឃើញ និងសូមស្នើសុំសេចក្ដីបញ្ជាក់ដ៏ខ្ពង់ខ្ពស់ពីឯកឧត្ដមរដ្ឋមន្ត្រី

ប្រធានសហព័ន្ធសហជីព

*(ករណីដែលសហជីពនោះជាសមាជិករបស់សហព័ន្ធសហជីពណាមួយ)*